**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**

**គណៈកម្មាធិការលទ្ធកម្ម**

លេខ: ...៥៨១៣... PC.អក

# សេចក្តីជូនដំណឹង(លើកទី២)

## ស្តីពី

ការផ្គត់ផ្គង់ ក្រដាស-ប៊ិច-សៀវភៅ និងសម្ភារផ្សេងៗ ចំនួន 229 មុខ
ជូន អគ្គិសនីកម្ពុជា(ភ្នំពេញ) សម្រាប់ឆ្នាំ 2021

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ៖ អគ្គិសនីកម្ពុជា នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់ ក្រដាស-ប៊ិច-សៀវភៅ និងសម្ភារផ្សេងៗ ចំនួន 229 មុខ ជូន អគ្គិសនីកម្ពុជា(ភ្នំពេញ) សម្រាប់ឆ្នាំ 2021 ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជាដែលមានអាសយដ្ឋាន៖ អាគារលេខ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០២០ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 023 67 66 007, 092 65 23 57 និង Website : www.edc.com.kh) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃនៅម៉ោង ១៤:០០ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០២០ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មតាមអាសយដ្ឋានខាងលើវេលាម៉ោង ១៥:១៥ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០២០ ។

ក្រុមហ៊ុន/សហគ្រាសដែលចូលរួមដាក់ឯកសារដេញថ្លៃ ស្នើសុំភ្ជាប់បន្ថែមមកជាមួយនូវឯកសារដេញថ្លៃ ដែលបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងភ្ជាប់មកជាមួយនូវ Soft Copy ដែលជាឯកសារ Scan របស់ឯកសារដេញថ្លៃនេះ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃនិងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃព្រហ. ១១កើត ខែ មិគសិរ ឆ្នាំ ជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០២០

**ជ- ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ហង់_ឆុច**

<u>ចម្លងជូន៖</u>

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ